MAJJHIMARAM Temple

HISTOIRES DE VIE MONTRÉAL
MONTREAL LIFE STORIES

www.cambodia.ca

Groupe de travail Cambodge — Cambodian Working Group

www.CURAKHMER.org

# កម្ពុជា វិបាកដ៏លើសលប់នៃការប្រល័យពូសាសន៍...

## សិក្ខាសាលាថ្នាក់អន្តរជាតិស្តីពី

## កម្ពុជាពីអតីតកាលមកទល់បច្ចុប្បន្ន លទ្ធផលនៃការចងចាំនិងអត្តសញ្ញាណដ៏ច្រើន

## ថ្ងៃទី៥ ៦ និង ៧ ឧសភា ២០១១ នាសកលវិទ្យាល័យកុងកកឌីយ៉ា ម៉ុងរេអាល់

ម៉ុងរេអាល់ ថ្ងៃចន្ទ័ទី ២៨កុម្ភៈ ២០១១- សិក្ខាសាលាថ្នាក់អន្តរជាតិស្តីពី«កម្ពុជាពីអតីតកាលមកទល់បច្ចុប្បន្ន លទ្ធផលនៃការចងចាំនិងអត្តសញ្ញាណដ៏ច្រើន» នឹងប្រព្រឹត្តទៅនៅថ្ងៃទី៥ ៦ និង ៧ ឧសភា ២០១១ នៅសកលវិទ្យាល័យកុងកកឌីយ៉ាម៉ុងរេអាល់។ ព្រឹត្តិការណ៍នេះត្រូវបានរៀបចំឡើងដោយក្រុមការងារ (www.curakhmer.org) កម្ពុជាសម្ព័នភាពនៃការស្រាវជ្រាវរវាងសកលវិទ្យាល័យនិងសហគមន៍ «ជីវប្រវត្តិរបស់អ្នកម៉ុងរេអាល់ដែលបានរងគ្រោះដោយសារសង្គ្រាម ការប្រល័យពូជសាសន៍ អំពើហឹង្សាផ្សេងៗលើសិទ្ធិបុគ្គល» ដែលមានមូលដ្ឋាននៅសកលវិទ្យាល័យកុងកកឌីយ៉ា។

សិក្ខាសាលានេះនឹងទទួលសិល្បៈករ សមិទ្ធិករភាពយន្តប្រមាណម្ភៃរូបព្រមទាំងអ្នកជំនាញខ្មែរនិងអន្តរជាតិជាច្រើនរូប ពីមុខវិជ្ជាផ្សេងៗជាអាទិ៍ ប្រវត្តិសាស្ត្រ ច្បាប់ ចិត្តសាស្ត្រ និងសង្គមសាស្ត្រ។ យើងទទួលសមិទ្ធិករភាពយន្តបារាំង-ខ្មែរដ៏ល្បីល្បាញគឺលោក ប៉ាន់ រីទ្ធី ជាអ្នកដែលធ្លាប់ទទួលរង្វាន់ជាញឹកញាប់ពីមហោស្រពទីក្រុងកាននិងរង្វាន់អន្តរជាតិជាច្រើនទៀត អ្នកនិពន្ធសៀវភៅរឿងគំនូរបារាំង-ខ្មែរ សេរ៉ាសេដ្ឋកិច្ចវិទូអាមេរិកាំង-ខ្មែរនិងជាអ្នករួចពីស្លាប់នៃរបបប្រល័យពូជសាសន៍គឺលោក អៀរ សុផល នរកវិទូ ហ៊ីនតុន អាឡិច អ្នកកាសែតបិកក័រ អេលីសាបែត នៃ New York Times សុទ្ធសឹងជាអ្នកឯកទេសប្រវត្តិសាស្ត្រស្រុកខ្មែរ នៅមានលោក ប៊ីទី រ៉ូបែរ ជាអតីតសហព្រះរាជអាជ្ញាអង្គជំនុំជម្រះវិសាមញ្ញនៃតុលាការកម្ពុជា។

សិក្ខាសាលាជាភាសាបារាំង-អង់គ្លេសនេះចង់ស្វែងយល់ពីមូលហេតុនិងដំណើរដែលរបបប្រល័យពូជសាសន៍ខ្មែរក្រហមបានធ្វើឲ្យអត្តសញ្ញាណខ្មែរទាំងក្នុងនិងក្រៅប្រទេសមានការផ្លាស់ប្តូរ។ ព្រឹត្តិការណ៍នេះជាឱកាសដ៏កម្រដែលលោកអ្នកអាចស្វែងយល់ពីប្រវត្តិសាស្ត្រកម្ពុជា និងជីវប្រវត្តិបងប្អូននៃសហគមន៍ខ្មែរនៅម៉ុងរេអាល់តាមរយៈ សាក្សីផ្ទាល់ខ្លួន ការស្រាវជ្រាវនានា ភាពយន្ត រឿងល្ខោនដែលជាផ្លែផ្កានៃការសិក្សារបស់ Histoires de vie Montréal តាំងពីបួនឆ្នាំមក។

Histoires de vie Montréal...(www.histoiresdeviemontreal.ca) គឺជាគំរោងស្រាវជ្រាវរយៈពេល១៥ឆ្នាំដឹកនាំដោយអ្នកស្រាវជ្រាវកំរិតខ្ពស់និងសហគមន៍ចំនួន៤០រូបនិងអង្គការ២០ដែលបានសិក្សាលើសហគមន៍វប្បធម៌ផ្សេងៗនៅម៉ុងរេអាល់រួមមាន ពួកហ្ស៊ីវ រ៉ូវ៉ាន់ដា ខ្មែរហាអ៊ីទី។ល។ គំរោងស្រាវជ្រាវនេះផ្តោតលើវិស័យផ្សេងៗដូចជា៖ ការអប់រំ សិល្បៈ ការការពារសិទ្ធិមនុស្ស។ គំរោងស្រាវជ្រាវនេះក៏មានភារៈប្រមូលនូវរឿងតំណាលផ្ទាល់មាត់របស់អ្នកស្រុកម៉ុងរេអាល់ទាំងនោះ រឿងតំណាលដែលបានថតជាកុននិងឌីជីតាល់ទុកដើម្បីបង្កើតជាឃ្លាំងផ្ទុកទិន្នន័យមួយដែលមនុស្សគ្រប់រូបអាចចូលទៅមើលបាន។

បើមានចម្ងល់សូមអញ្ជើញទាក់ទង៖


Marita Arnold (ភាសាអង់គ្លេស), (514) 564-7015, maritaarnold@gmail.com

Nolsina Yim (ភាសាបារាំង), (514) 312-5046, yim@nolsina.com

Ravann Runnath (ភាសាខ្មែរ), (514) 812- 4683, r.runnath@gmail.com

www.curakhmer.org/media